មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

# របាយការណ៍

## វគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តន៍យុទ្ធសាស្ត្រ
## បង្កើនការស្រាវជ្រាវរកករណីជំងឺរបេង ការព្យាបាលបង្ការជំងឺរបេង
## ដោយប្រើឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេង
## (យុទ្ធសាស្ត្រ Three I's)

## Training On The Implementation of Three I's Strategy

ថ្ងៃទី ២៧- ២៨ ខែ ធ្នូ ឆ្នាំ ២០១០

បន្ទប់ប្រជុំមន្ទីរពេទ្យកុមារជាតិ

រៀបចំដោយ

ឧបត្ថម្ភដោយ

## ១~ សមាសភាពចូលរួមមាន :

គណៈអធិបតីដែលចូលរួមក្នុងពិធីបើកវគ្គនេះមានៈ

O ឯកឧត្តមវេជ្ជ **មាន ឈីវុន** ប្រធានមជ្ឍប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

សិក្ខាកាមដែលចូលរួម មានចំនួន ៦១ រូប ដែលជាសមាជិកក្រុមថែទាំ-ព្យាបាលជំងឺអេដស៍ លើកុមារ និង មនុស្សពេញវ័យ ,សេវាជំងឺរបេង,មន្ទីរពិសោធន៍,ក្រុមថែទាំតាមផ្ទះ,អ្នកសំរបសំរួល MMM និង mmm អ្នកផ្តល់ប្រឹក្សាផ្ទៃក VCCT ដែលអញ្ជើញមកពី ស្រុកប្រតិបត្តិដូនកែវ ខេត្តតាកែវ ស្រុកប្រតិបត្តិកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ស្រុកប្រតិបត្តិឧដុង្គ ខេត្តកំពង់ស្ពឺ មន្ទីរពេទ្យព្រះសីហនុ និងគ្លីនិកសុខភាពសង្គម។

## ២~ អ្នកសំរបសំរួលវគ្គ/អ្នកចូលរួម :

| | | |
|---|---|---|
| ១- | លោកវេជ្ជ. សេង សុភាព | មជ្ឍមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ |
| ២- | លោកវេជ្ជ. សរិត សុវណ្ណរិទ្ធិ | មជ្ឍមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ |
| ៣- | លោកវេជ្ជ. ស៊ីម សុផៃ | មជ្ឍមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ |
| ៤- | អ្នកសំរបសំរួល ចំនួន០៤រូប | មជ្ឍមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន |
| ៥- | គណនេយ្យករ ចំនួន០២រូប | មជ្ឍមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ |
| ៦- | រដ្ឋបាល ចំនួន០២រូប | មជ្ឍមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ |

## ៣~ សកម្មភាព :

**គោលបំណងៈ**

- ផ្តល់ពតិមាន ស្តីពីខ្លឹមសារនៃនិយាមបែបបទ សំរាប់អនុវត្តការបង្កើតការស្រាវជ្រាវ រកករណីជំងឺរបេង ការព្យាបាលបង្ការជំងឺរបេងដោយឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេងនៅតាមបណ្តាសេវាថែទាំ និងព្យាបាលបន្ត សំរាប់អ្នកផ្ទុក មេរោគអេដស៍ ។
- បង្កើនចំណេះដឹង និងជំនាញចាំបាច់ទាក់ទងនឹងការអនុវត្តន៍យុទ្ធសាស្រ្ត 3I's ជូនដល់មន្ត្រីផ្តល់សេវាថែទាំ-ព្យាបាល សំរាប់អ្នកផ្ទុកមេរោគអេដស៍ ដោយផ្តោតលើ ប្រធានបទខាងក្រោមៈ
  - ១- បង្កើនការស្រាវជ្រាវអ្នកជំងឺរបេងថ្មី ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ថ្មី តាមរយៈការសាកសួររករោគសញ្ញាទាំងបី
  - ២- ការប្រើប្រាស់គំនូសបំព្រួញសំរាប់ការផ្តល់ការព្យាបាលបង្ការជំងឺរបេងដោយ ប្រើឱសថ Isoniazid (IPT)

៣- ការពិនិត្យសុខភាពរករោគសញ្ញាជំងឺរបេងដោយប្រើប័ណ្ណពិនិត្យសុខភាពរក រោគសញ្ញាជំងឺរបេងសំរាប់អ្នកផ្ទុកមេរោគអេដស៍ និងការព្យាបាលបង្ការជំងឺរបេង ដោយប្រើឱសថ Isoniazid (IPT)

៤- ការធ្វើរោគវិនិច្ឆ័យច្បាស់លាស់ (diagnostic workup) រកជំងឺរបេងក្នុង ចំណោមអ្នកផ្ទុកមេរោគអេដស៍

៥- ចំណេះដឹងមូលដ្ឋានស្តីអំពីការធ្វើតេស្តទុយប៊ែគុលលីន លើស្បែក (Tuberculin Skin Test-TST)

៦- ការផ្តល់ការគាំទ្រសំរាប់ការប្រើប្រាស់ឱសថ Isoniazid ឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ក្នុងការផ្តល់ IPT

៧- ការបង្ការការចំលងមេរោគរបេងនៅតាមបណ្តាសេវាថែទាំ និងព្យាបាលបន្ត

៨- ការប្រមូលទិន្នន័យ ដោយប្រើឧបករណ៏ត្រួតពិនិត្យតាមដាននៃនិយាមនៃ បែបបទសំរាប់អនុវត្តយុទ្ធសាស្រ្ត 3Is

- រៀបចំផែនការ សំរាប់យុទ្ធសាស្រ្ត 3Is នៅសេវាថែទាំ-ព្យាបាលបន្ត សំរាប់អ្នកផ្ទុក មេរោគ អេដស៍

**ថ្ងៃទី១: ២៧ ខែ ធ្នូ ឆ្នាំ ២០១០**

o ចំណាប់អារម្មណ៏ និងពិធីបើកវគ្គដោយ ឯកឧត្តមវេជ្ជ **មាន ឈីវុន** ប្រធានមជ្ឈប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

☞ ការបង្ហាញពីកម្មវិធី និងគោលនៃកិច្ចប្រជុំ ដោយ**លោកវេជ្ជ. សិរិត សុវណ្ណរិទ្ធិ**

☞ ការបង្ហាញពីផ្តល់ពតិមាន ស្តីពីខ្លឹមសារនៃនិយាមបែបបទ សំរាប់អនុវត្តការបង្កើតការ ស្រាវជ្រាវរកករណីជំងឺរបេង ការព្យាបាលបង្ការជំងឺរបេងដោយឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេង នៅតាមបណ្តាសេវាថែទាំ និងព្យាបាលបន្ត សំរាប់អ្នកផ្ទុកមេរោគ អេដស៍ ដោយ**លោកវេជ្ជ. សិរិត សុវណ្ណរិទ្ធិ និង ឃុន គីម អ៊ាម**

☞ ការពិភាក្សាទូទៅ **សំរបសំរួលដោយមន្ត្រី** NCHADS & CENAT

☞ ការព្យាបាលបង្ការជំងឺរបេងដោយឱសថ Isoniazid បង្ហាញដោយ **វេជ្ជ ស៊ីម សូផៃ**

☞ ការពិនិត្យសុខភាពរករោគសញ្ញាជំងឺរបេងដោយប្រើបណ្ណ័ពិនិត្យសុខភាពរោគ សញ្ញាជំងឺរបេង បង្ហាញដោយ **វេជ្ជ ស៊ីម សូផៃ**

☞ ការធ្វើរោគវិនិច្ឆ័យច្បាស់លាស់ (Diagnostic Workup) រកជំងឺរបេង បង្ហាញដោយ **លោកវេជ្ជ. ឃុន គីម អ៊ាម/ ជា ម៉ានិត**

☞ ការផ្តល់ការគាំទ្រ សំរាប់ការប្រើប្រាស់ឱសថ អោយបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ក្នុងការផ្តល់ការព្យាបាលបង្ការជំងឺរបេង ដោយឱសថ Isoniazid

បង្ហាញដោយ **លោកវេជ្ជ.** សេង សុភាពនិង វេជ្ជ ស៊ឹម សុផៃ

**ថ្ងៃទី២: ២៨ ខែ ធ្នូ ឆ្នាំ ២០១០**

☞ ការបង្ការការចំលងមេរោគរបេង នៅតាមបណ្តាសេវា ថែទាំ-ព្យាបាលបន្ត

បង្ហាញដោយ **លោកវេជ្ជ. ជា ម៉ានិត**

☞ ការប្រមូលទិន្នន័យ ដោយប្រើឧបករណ៍ ត្រួតពិនិត្យតាមដាននៃ និយាមនៃបែបបទ សំរាប់ អនុវត្តយុទ្ធសាស្រ្ត Three I's បង្ហាញដោយ**លោក** ផាត់ វាសនា

☞ ការពិភាក្សាជាក្រុមៈ **ការលើកផែនការ សំរាប់អនុវត្តនូវសកម្មភាពនៃការ អនុវត្តន៍យុទ្ធសាស្រ្ត** Three I's **នៅសេវាថែទាំ-ព្យាបាលបន្ត** សំរបសំរួលដោយមន្ត្រី NCHADS និង CENAT

☞ ការបង្ហាញពីលទ្ធផលនៃការពិភាក្សាជាក្រុម **សំរបសំរួលដោយមន្ត្រី** NCHADS និង CENAT

## លទ្ធផលនៃការវាយតំលៃកិច្ចប្រជុំ :

| | **វែងពេក** | **សមរម្យ** | **ខ្លី** | **ខ្លីពេក** |
|---|---|---|---|---|
| ១. រយៈពេល | ០០ | ១៥ | ២៧ | ០០ |
| | **ល្អ** | **បង្គួរ** | **មធ្យម** | **ខ្វះខាត** |
| ២. ទីកន្លែង | ៣៨ | ០២ | ០២ | ០០ |
| ៣. ការរៀបចំវគ្គបណ្តុះបណ្តាល | ២៥ | ១៥ | ០២ | ០០ |
| ៤, ខ្លឹមសារមេរៀន | ២៨ | ១០ | ០៤ | ០០ |
| ៥. ការបង្រៀន និងការសំរបសំរួល | ២០ | ១៥ | ០៧ | ០០ |
| ៦. ឯកសារសំរាប់សិក្ខាកាម | ៣០ | ០៨ | ០៤ | ០០ |

៧. ចំណេះដឹង និងជំនាញ ចំនួន បី ដែលសិក្ខាកាមបានទទួលពីវគ្គបណ្តុះបណ្តាល

៧.១- <u>ចំណេះដឹង</u>

- ការស្រាវជ្រាវជំងឺរបេង
- ការគ្រប់គ្រងការចំលងរោគរបេង
- ការបំពេញទំរងបញ្ជូន
- ការថែទាំ និងព្យាបាលបន្ត

៧.២- <u>ជំនាញ</u>

- រោគសញ្ញារបេង
- កែសំរួលប្រពន្ធ័ខ្យល់
- ការផ្តល់ឱសថ អ៊ីសូឌីញ៉ាស៊ីដ
- បញ្ជូនរបាយការណ៍

៨. តើមានប្រធានបទណាខ្លះ ដែលអ្នកចង់ដាក់បញ្ចូលបន្ថែមទៀត នៅក្នុងសិក្ខាសាលា?

២. ប្រធានបទ ស្តីពីការថត X-Ray

៣. ប្រធានបទ ស្តីពីរបៀបធ្វើតេស្តរបេង លើកុមារ និងកំហុសឆ្គងទាំងឡាយណា ដែលនាំអោយតេស្តរបេង មិនធម្មតា

៩. តើអ្នកយល់ថា ត្រូវកែលំអវគ្គសិក្ខាសាលានេះ យ៉ាងដូចម្តេច ដើម្បីអោយមានលក្ខណៈប្រសើរ សំរាប់វគ្គក្រោយៗទៀត?

១. រយៈពេលខ្លីពេក

២. Slides មួយចំនួនជាភាសារ English ពិបាកយល់

១០. សំណូមពរ សំរាប់វគ្គក្រោយ

១. សុំវគ្គបណ្តុះបណ្តាលនេះ វែងជាងនេះបន្តិច

២. សុំប្រាក់លើកទឹកចិត្ត

៣. សុំ ម៉ាស និងស្រោមដៃ ដើម្បីប្រើប្រាស់

៤. សុំស្រោមអនាម័យ

៥. សុំចុះអភិបាលអោយបានញឹកញាប់

ពិធីបិទវគ្គប្រព្រឹត្តទៅ ដោយមានវគ្គមានគណអធិបតីរចូលរួមដូចជា

- កិច្ចប្រជុំនេះបានបញ្ចប់ដោយជោគជ័យនៅវេលាម៉ោង ៥និង ០០ នាទី ល្ងាច បន្ទាប់ពីបានបូកសរុបកិច្ចប្រជុំ និងការថ្លែងសុន្ទរកថាបិទដោយ ឯកឧត្តមវេជ្ជ មាន ឈីវុន ប្រធានមជ្ឈប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

បានឃើញ និងឯកភាព

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ

នឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

វេជ្ជ មាន_ឈីវុន

ភ្នំពេញថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០

អ្នកធ្វើរបាយការណ៍

វេជ្ជ ស៊ឹម សុផៃ